ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

លេខ:.........

# សេចក្តីប្រកាសព័ត៌មាន

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សូមជម្រាបជូនសាធារណៈជនមេត្តាជ្រាបថា យោងតាមប្រកាសអន្តរក្រសួងលេខ១៤៤១៤ ប្រ.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់ថ្លៃសេវាលិខិតឆ្លងដែនធម្មតាដូចខាងក្រោម៖

១- សេវារយៈពេល២០ថ្ងៃ តម្លៃ០១ក្បាល ១០០ដុល្លារសហរដ្ឋអាមេរិក

២- សេវារយៈពេល១០ថ្ងៃ តម្លៃ០១ក្បាល ១៥០ដុល្លារសហរដ្ឋអាមេរិក

៣- សេវារយៈពេល០១ថ្ងៃ តម្លៃ០១ក្បាល ២០០ដុល្លារសហរដ្ឋអាមេរិក

ដោយឡែកចំពោះពលករទៅបំពេញការងារស្របច្បាប់នៅក្រៅប្រទេស តាមរយៈក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់លិខិតធ្វើដំណើរត្រូវផ្តល់ដោយឥតគិតថ្លៃដោយអាករជាបន្ទុករបស់រដ្ឋ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សូមជម្រាបជូនដំណឹងដល់សាធារណៈជនមេត្តាជ្រាបថា ដើម្បីជៀសវាងការឆ្លៀតឱកាសយកកម្រៃសេវាលើសការកំណត់ដូចបានជម្រាបជូនខាងលើ ពីសំណាក់ក្រុមហ៊ុនជ្រើសរើសពលករ ឬមេខ្យល់ ឬអ្នករត់ការយកកម្រៃជើងសារ សូមប្រជាពលរដ្ឋដែលមានបំណងសុំផ្តល់លិខិតឆ្លងដែនធម្មតា មេត្តាទំនាក់ទំនងដោយផ្ទាល់ជាមួយ៖

- នាយកដ្ឋានលិខិតឆ្លងដែនដែលមានអាសយដ្ឋានស្ថិតក្នុង ភូមិតាង៉ូវ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមទូរស័ព្ទលេខ ០៦៩៩២៣៨៣៨

ចំពោះពលករបំពេញការងារស្របច្បាប់នៅក្រៅប្រទេស ដោយមានការទទួលស្គាល់ និងមានលិខិតបញ្ជាក់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមមេត្តាទំនាក់ទំនងដោយផ្ទាល់ជាមួយ៖

- នាយកដ្ឋានលិខិតឆ្លងដែនដែលមានអាសយដ្ឋានស្ថិតក្នុងភូមិតាង៉ូវ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមទូរស័ព្ទលេខ ០៦៩៩២៣៨៣៨
- សាខាលិខិតឆ្លងដែនប្រចាំខេត្តបាត់ដំបងមានអាសយដ្ឋានស្ថិតក្នុងភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ឬតាមរយៈទូរស័ព្ទលេខ ០៧០៨៦៨៦៨៨
- សាខាលិខិតឆ្លងដែនប្រចាំខេត្តបន្ទាយមានជ័យមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ៥២-៥៤ ភូមិគីឡូម៉ែត្រលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឬតាមរយៈទូរស័ព្ទលេខ ០៦១២២១១៩៨

សូមបញ្ជាក់ជូនថា សាខាលិខិតឆ្លងដែនប្រចាំខេត្តទាំងពីរខាងលើ ផ្តល់ជូនតែលិខិតធ្វើដំណើរជូនពលករធ្វើការនៅបរទេសប៉ុណ្ណោះ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម សង្ឃឹមជឿជាក់ថាសាធារណៈជនទាំងអស់នឹងធ្វើទំនាក់ទំនងដោយផ្ទាល់មកកាន់ទីតាំងទាំង០៣ ឬតាមរយៈទូរស័ព្ទខាងលើ ដើម្បីទទួលបានព័ត៌មានពិតប្រាកដជៀសវាងបាននូវការខាតបង់ទាំងប្រាក់កាសនិងពេលវេលា។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៧*